PUBLICITÉ




PUBLICITÉ



កម្ពុជា - អត្ថបទចុះផ្សាយនៅថ្ងៃ សៅរ៍ 20 វិច្ឆិកា 2010 - ព័ត៌មានទើបកែប្រើលើកចុងក្រោយ ថ្ងៃ សៅរ៍ 20 វិច្ឆិកា 2010

# អង្គការសង្គមស៊ីវិលស្នើរដ្ឋាភិបាលចូលរួមជជែកច្បាប់គ្រប់គ្រងអង្គការ

**ដោយ អ៊ុំ ណារិន**


រដ្ឋសភាកម្ពុជាស្ថាប័នសម្រាប់តាក់តែងច្បាប់
© ដីលុច

**រដ្ឋាភិបាលគ្រោងផ្ញើសេចក្តីព្រាងច្បាប់គ្រប់គ្រងអង្គការសមាគមក្រៅរដ្ឋាភិបាលទៅសភាអនុម័តក្នុងពេលឆាប់ៗនេះ។ ប៉ុន្តែអង្គការសង្គមស៊ីវិលស្នើសុំរដ្ឋាភិបាលចូលរួមពិនិត្យផ្តល់យោបល់ជាមុនសិនមុនបញ្ជូនសេចក្តីព្រាងច្បាប់នេះទៅរដ្ឋសភា។ អ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រីហៅសំណើរបស់សង្គមស៊ីវិលនោះ ថាដើរមិនស្របស្ថានភាពនីតិរដ្ឋនៅកម្ពុជា។ ប៉ុន្តែ បក្សប្រឆាំងវិញថាច្បាប់នេះ នឹងនាំកម្ពុជាទៅរករបបកុម្មុយនិស្ត។**

**សេចក្តីរាយការណ៍របស់អ៊ុំ ណារិន**
20/11/2010
by អ៊ុំ ណារិន
ស្តាប់ (03:22) +

ក្រុមអង្គការសង្គមស៊ីវិលជាតិនិងអន្តរជាតិចំនួន៨០ស្ថាប័នបានអំពាវនាវរួមគ្នាដល់រដ្ឋាភិបាល អោយបើកលទ្ធភាពដល់បណ្តាអង្គការក្រៅរដ្ឋាភិបាលបានចូលទៅអង្គុយជជែកជាមួយមន្ត្រីជំនាញលើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងអង្គការសមាគមក្រៅរដ្ឋាភិបាល មុនសេចក្តីព្រាងច្បាប់គ្រប់គ្រងអង្គការសមាគមក្រៅរដ្ឋាភិបាលនេះ ដាក់ទៅរដ្ឋសភាអនុម័ត។

សេចក្តីអំពាវនាវរបស់ក្រុមសង្គមស៊ីវិលទាំងនោះកើតចេញបន្ទាប់ពីពួកគេបានជួបជុំគ្នាកាលពីថ្ងៃទី១៨វិច្ឆិកាកន្លងទៅនេះក្នុងការធ្វើវិភាគទៅលើច្បាប់គ្រប់គ្រងអង្គការក្រៅរដ្ឋាភិបាលមកពីប្រទេសចំនួន៧០។

បច្ចុប្បន្នកម្ពុជាមិនមានច្បាប់គ្រប់គ្រងអង្គការអោយចំតែម្តងនោះទេ។ អង្គការក្រៅរដ្ឋាភិបាលនៅកម្ពុជាប្រមាណ ៣ ០០០ស្ថាប័ន បានសុំការអនុញ្ញាតពីក្រសួងមហាផ្ទៃដោយសំអាងលើច្បាប់មួយចំនួនដូចជាច្បាប់ព្រហ្មទណ្ឌជាដើម។

រដ្ឋាភិបាលបានតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងអង្គការសមាគមក្រៅរដ្ឋាភិបាលតាំងពីឆ្នាំ២០០៥មកម្ល៉េះ។ យោងតាមក្រុមអង្គការសង្គមស៊ីវិលអោយដឹងថារដ្ឋាភិបាលគ្រោងផ្ញើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងអង្គការសមាគមក្រៅរដ្ឋាភិបាលនេះទៅរដ្ឋសភាអនុម័តនៅចុងឆ្នាំ២០១០នេះ។ ក៏ប៉ុន្តែ រហូតមកដល់ពេលនេះ រដ្ឋាភិបាលមិនបានបង្ហាញសេចក្តីព្រាងច្បាប់នោះអោយសង្គមស៊ីវិលបានឃើញនោះទេ។

ក្រុមអង្គការសង្គមស៊ីវិលមានការព្រួយបារម្ភខ្លាចរដ្ឋាភិបាលបង្កើតច្បាប់នេះឡើងក្នុងគោលបំណងបង្កការលំបាកដល់ការបំពេញការងារ របស់សង្គមស៊ីវិលនៅកម្ពុជា។ លោក អ៊ូ វីរៈប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាដែលជាសមាជិកមួយក្នុងចំណោមស្ថាប័ន អង្គការទាំង៨០នោះបានលើកឡើងថាមានចំនុចសំខាន់ជាច្រើនដែលសង្គមស៊ីវិលរកឃើញថា អាចបង្កការលំបាកដល់សង្គមស៊ីវិលប្រសិនរដ្ឋាភិបាលដាក់ចំនុចទាំងនោះចូលក្នុងសេចក្តីព្រាងច្បាប់នោះ។

ចំណុចសើបទាំងនោះរួមមានរួមមាន បែបបទការចុះបញ្ជីឈ្មោះ ការកំណត់ចំនួនសមាជិករបស់អង្គការនីមួយៗក្នុងបរិមាណច្រើននាក់។ ការឃ្លាំមើលអង្គការសង្គមស៊ីវិលតាមរយៈត្រូវអនុញ្ញាតអោយមន្ត្រីរដ្ឋាភិបាលចូលរួមកិច្ចប្រជុំផ្ទៃក្នុងរបស់អង្គការសង្គស៊ីវិលនិងការគ្រប់គ្រងថវិការបស់អង្គការសង្គមស៊ីវិលដោយរួមទាំងសេដ្ឋកិច្ចហិរញ្ញវត្ថុជាដើម។



**ស្តាប់វិទ្យុបារាំងអន្តរជាតិ**
ការផ្សាយផ្ទាល់ | ព័ត៌មាន | បទភ្លេង | RFI បារាំង
ស្តាប់ការផ្សាយបន្តផ្ទាល់

**ស្តាប់ការផ្សាយមុនៗ**



ចុចត្រង់នេះដើម្បីស្តាប់ការផ្សាយមុនៗ

Jobs à la Une sur monster — Voir plus d'offres

COMMERCIAL SEDENTAIRE BILINGU...
METAL INDUSTRIEL possède depuis plus d...
Picardie

Responsable Marketing et Comm...
GROUPAUTO, société leader de la distri...
Bretagne

Responsable de résidence H/F
Société de promotion et gestion immobi...
Rhône Alpes

Ingénieur système dans un Hed...
Durée de la mission : indéterminée Dat...
Ile de France




**សេវា វិទ្យុបារាំងអន្តរជាតិ**
- សរសេរមកយើង
- អន្តរការិនី
- កន្លែងសម្រាប់អ្នកសារព័ត៌មាន
- សេវាំអាជីព

**ទទួលព័ត៌មានពីRFI**
- ចាប់រលកធាតុអាកាសRFI
- តាមទូរស័ព្ទដៃ
- តាម RSS
- តាម Dailymotion
- តាម Twitter
- តាម Facebook
- តាម Podcast
- តាមព្រឹត្តបត្តិព័ត៌មាន

**អត្ថបទដែលពេញនិយមជាងគេ**
អានច្រើនជាងគេ | មានប្រតិកម្មច្រើនជាងគេ

09/04/2010
**ធ្វើយ៉ាងណាដើម្បីស្តាប់ការផ្សាយរបស់វិទ្យុ RFI?**

29/01/2011 - កម្ពុជា
**ស្ថានការណ៍នៅព្រះវិហារបន្តតានតឹងនៅថ្ងៃនេះ**

28/01/2011 - កម្ពុជា-ថៃ
**ស្ថានភាពយោធានៅព្រំដែនព្រះវិហារតានតឹងសាជាថ្មីនៅថ្ងៃនេះ**

26/01/2011 - កម្ពុជា
**កម្ពុជា ដកផ្ទាំងអក្សរចារឹក ដែលសម្គាល់ពីទីកន្លែងកងទ័ពថៃចលឈានពាន**

លោក អ៊ូ វីរៈ បានបញ្ជាក់ថា ចំនុចទាំងនោះគឺជាការលំបាកយ៉ាងខ្លាំងក្នុងការបង្កើតនិងដំណើររបស់អង្គការនៅកម្ពុជាដោយឯករាជ្យ។ លោកបន្តថាប្រសិនសង្គមស៊ីវិលបានអង្គុយជជែកជាមួយមន្ត្រីរដ្ឋាភិបាលមុនសេចក្តីព្រាងច្បាប់នេះផ្ញើទៅរដ្ឋសភាចំនុចអវិជ្ជាមាន ទាំងនោះអាចដោះស្រាយបាន។

លោក ផៃ ស៊ីផាន រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាអ្នកនាំពាក្យទីស្តីការគណៈរដ្ឋមន្ត្រី បានមានប្រសាសន៍ថា លោក មិនទាន់បានឃើញសេចក្តីព្រាងច្បាប់នោះនៅឡើយទេ។ប៉ុន្តែ មន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលរូបនេះពន្យល់ថា នៅកម្ពុជាមានស្ថាប័នតែពីរប៉ុណ្ណោះ មានសិទ្ធិតាក់តែងច្បាប់។ ទី១ រដ្ឋសភានិងទី២ រដ្ឋាភិបាល។ លោក ផៃ ស៊ីផានបានហៅការព្រួយបារម្ភរបស់សង្គមស៊ីលវិលថាជាសកម្មភាពមួយដែលបានដើរមិនសមស្របជាមួយស្ថានភាព នីតិរដ្ឋ នៅកម្ពុជា។

កម្ពុជាមិនគួរមានច្បាប់គ្រប់គ្រងអង្គការសមាគមនោះទេ នេះជាប្រសាសន៍របស់លោក ស៊ុន ឆៃ។ លោកស៊ុន ឆៃ សមាជិករដ្ឋសភា គណបក្ស សម រង្ស៊ី បានហៅច្បាប់គ្រប់គ្រងអង្គការសង្គមស៊ីវិលនឹងនាំកម្ពុជាទៅរករបបកុម្មុយនីស្ត៕

TAGS: កម្ពុជា

បោះពុម្ព | ផ្ញើទំព័រនេះ | ថត | ចែកចាយ

30/01/2011 - កម្ពុជា

**កម្ពុជានឹងធ្វើម្ចាស់ផ្ទះកិច្ចចរចារកដំណោះស្រាយនយោបាយប្រទេសនេប៉ាល់**

**RFI STORE**







**Free Khmer Chat room**
Chat with Khmer and make friends. Chat and Watch Khmer movie at once.
Annonces Google

**ការផ្សាយ**
តាមចំណាងជើង
តាមឈ្មោះអ្នកកាសែត
ព័ត៌មាន
ភាសាបារាំងងាយយល់

**ការលក់ទំនិញ**
ទំព័រដើមនៃការលក់
សៀវភៅ
ថាស CD DVD
បណ្ណសារសំឡេង
បទភ្លេងអន្តរជាតិ

**ទាក់ទងនឹងវិទ្យុយើង**
ស្តីពីRFI
កន្លែងសម្រាប់អ្នកសារព័ត៌មាន
ការប្រឡងប្រជែង
សរសេរមកកាន់យើង

**សេវាអាជីព**
ទំព័រដើមនៃសេវាអាជីព
Talent+
MFI
ផ្សាយបន្តកម្មវិធីយើង
Habillage antenne
Ordispace
Planète radio

**សេវា**
តារាងកម្មវិធី
ចាប់ការផ្សាយRFI

**សាខា**
Monte Carlo Doualiya
RFI Roumanie
Radio Europa Lisboa

**ភាសាបរទេស**
ភាសាអង់គ្លេស
ភាសាពែក្ស
ភាសាអារ៉ាប់
ភាសាព័រទុយហ្គាល់
ភាសាបារាំង
ភាសារ៉ូមានី
ភាសាចិន
ភាសារុស្ស៊ី
ភាសាអូសា
ភាសាវៀតណាម
ភាសាអេស្ប៉ាញ